ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំចក្រភពអង់គ្លេស

# សេចក្តីប្រកាសព័ត៌មាន

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំចក្រភពអង់គ្លេស យោងតាមសេចក្តីជូនដំណឹងលេខ ២២៦សខល ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ក្រសួងសុខាភិបាល ស្តីពីការកែសម្រួលលក្ខខណ្ឌធ្វើដំណើរចូលមកប្រទេសកម្ពុជា ការអនុវត្តវិធានការសុខាភិបាល និងការធ្វើចត្តាឡីស័ក សូមជម្រាបជូនបងប្អូនប្រជាពលរដ្ឋ សិស្ស និស្សិតខ្មែរទាំងអស់ ដែលកំពុងរស់នៅ ស្នាក់នៅសិក្សានៅក្នុងចក្រភពអង់គ្លេសឱ្យបានជ្រាបនូវខ្លឹមសារសំខាន់ៗ នៃសេចក្តីជូនដំណឹងនេះ ដែលពាក់ព័ន្ធនឹងអ្នកធ្វើដំណើរជាជនជាតិខ្មែរដូចតទៅនេះ៖

១-អ្នកធ្វើដំណើរជាជនជាតិខ្មែរ ដែលប្រើប្រាស់លិខិតឆ្លងដែនកម្ពុជាឬលិខិតឆ្លងដែនបរទេស ដែលធ្វើដំណើរមកដល់ប្រទេសកម្ពុជា ត្រូវ៖

- អនុវត្តការធ្វើចត្តាឡីស័កពេញលេញ ក្រោយពីយកសំណាកវិភាគនៅទីតាំងរបស់រដ្ឋ ដែលបានកំណត់សម្រាប់រយៈពេល១៤ថ្ងៃ ដោយមិនគិតថ្លៃចំណាយក្នុងអំឡុងពេលអនុវត្តវិធានការសុខាភិបាល។
- មិនតម្រូវឱ្យមានការតម្កល់ប្រាក់ និងទិញសេវាធានារ៉ាប់រងសុខភាព (Health Insurance) សម្រាប់ព្យាបាលជំងឺកូវីដ-១៩។
- ក្នុងករណីអ្នកដំណើរស្នើសុំស្នាក់នៅក្នុងសណ្ឋាគារ ដែលកំណត់ដោយក្រសួងសុខាភិបាល រាល់ការចំណាយថ្លៃសេវារបស់សណ្ឋាគារ និងចំណាយផ្សេងៗក្នុងអំឡុងពេលស្នាក់នៅជាបន្ទុករបស់សាមីខ្លួន។
- អាជ្ញាធរសុខាភិបាលនឹងត្រូវយកសំណាក ដើម្បីធ្វើតេស្តក្នុករណីសង្ស័យណាមួយអំឡុងពេលចត្តាឡីស័ក និងត្រូវធ្វើតេស្តនៅថ្ងៃទី១៣ ដើម្បីបញ្ជាក់ នៃការបញ្ចប់ករណីចត្តាឡីស័ក។

64 Brondesbury Park, Willesden Green, London NW6 7AT, Tel: +44 20 8451 7850, Fax: +44 20 8451 7594
Email: cambodianembassy@btconnect.com Website: www.cambodianembassy.org.uk

២-ការប្រើប្រាស់ទីតាំងស្នាក់នៅរង់ចាំលទ្ធផលធ្វើតេស្តរកមេរោគកូវីដ-១៩ លើកទី១ និងការធ្វើចត្តាឡីស័ក៖

- អ្នកដំណើរជាជនជាតិខ្មែរ ដែលប្រើប្រាស់លិខិតឆ្លងដែនកម្ពុជា ឬលិខិតឆ្លងដែនបរទេសនឹងត្រូវបញ្ជូនទៅធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ នៅទីតាំងរបស់រដ្ឋ ដោយមិនតម្រូវឱ្យបង់ប្រាក់ថ្លៃអាហារ និងថ្លៃស្នាក់នៅ។ ករណី ដែលអ្នកដំណើរស្នើសុំទៅស្នាក់នៅសណ្ឋាគារ ដែលកំណត់ដោយក្រសួងសុខាភិបាល រាល់ការចំណាយពាក់ព័ន្ធថ្លៃស្នាក់នៅ និងចំណាយផ្សេងៗជាបន្ទុករបស់សាមីខ្លួន ដែលត្រូវទូទាត់ជូនសណ្ឋាគារ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមអ្នកដំណើរជាជនជាតិខ្មែរ ទោះជាប្រើប្រាស់លិខិតឆ្លងដែនកម្ពុជា ឬលិខិតឆ្លងដែនបរទេសមេត្តាជ្រាប និងចូលរួមសហការប្រកបដោយការទទួលខុសត្រូវ និងដើម្បីរួមគ្នាអនុវត្តវិធានការប្រយុទ្ធនឹងជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាលកម្ពុជាឱ្យមានប្រសិទ្ធិភាពខ្ពស់។

សេចក្តីជូនដំណឹងនេះនឹងអនុវត្តចាប់ពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ តទៅ។

ថ្ងៃចន្ទ ១កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ពស២៥៦៤
ទីក្រុងឡុងដ៍ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០